**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**សូមគោរពជូន**

**សម្តេចវិបុលបញ្ញា សុខ អាន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

***ជាទីគោរពដ៏ខ្ពង់ខ្ពស់!***

ខ្ញុំបាទ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទាំងអស់ សូមសម្តែងនូវសេចក្តីអំណរសាទរយ៉ាងកក់ក្តៅជាទីបំផុត ប្រកបដោយក្តីរំភើបរីករាយឥតឧបមា ជាមួយនឹងមនោសញ្ចេតនា គោរពស្រឡាញ់ដ៏ខ្ពង់ខ្ពស់បំផុត ចំពោះ **សម្តេច** ក្នុងឱកាសដែល **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ប្រោសព្រះរាជទានគោរមងារ **សម្តេចវិបុលបញ្ញា សុខ អាន** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៣១៧/២៦៧ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៧។

គោរមងារដែល **សម្តេច** ទទួលបាននាពេលនេះ គឺពិតជាស័ក្តិសមបំផុតចំពោះវីរភាពដ៏ឧត្តុងឧត្តមថ្លៃថ្លារបស់ **សម្តេច** ដែលជាអ្នកដឹកនាំដ៏ឆ្នើមមួយរូបរបស់ប្រជាជាតិខ្មែរយើង បានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតីពុះពារជំនះឧបសគ្គគ្រប់បែបយ៉ាង និងគ្រប់កាលៈទេសៈ ប្រកបដោយទឹកចិត្តស្វាមីភក្តិជានិច្ច ចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ ក្នុងការចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីស្តារ និងអភិវឌ្ឍប្រទេសជាតិលើគ្រប់វិស័យ ទទួលបាននូវសុខសន្តិភាព ឯកភាពជាតិ ស្ថិរភាពសង្គម ស្ថិរភាពនយោបាយ ពង្រឹងនីតិរដ្ឋ រក្សាការពារឯករាជ្យជាតិ និងបូរណភាពទឹកដី។

ក្នុងឱកាសដ៏បវរមហាប្រសើរប្រកបដោយកិត្តិយសដ៏ឧត្តុងឧត្តមនេះ យើងខ្ញុំ សូមគោរពជូនពរចំពោះ **សម្តេចវិបុលបញ្ញា និងលោកជំទាវ** ព្រមទាំងក្រុមគ្រួសារជាទីស្រឡាញ់ទាំងអស់ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ អាយុយឺនយូរ ជួបប្រទះតែសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចវិបុលបញ្ញា សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុត ពីយើងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៧

**តំណាងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩